## ក្រុមមេធាវីឃ្លាំមើលសិទ្ធិនៃប្រទេសកាណាដា

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣

កម្មវត្ថុ: ការគំរាមកំហែងដោយប្រពន្ធ័តុលាការ និងការឃុំឃាំងដោយខុសច្បាប់លើ **លោក គុជ វ៉េង**

ឯកឧត្តមជាទីគោរពរាប់អាន!

ខ្ញុំសរសេរក្នុងនាម ក្រុមមេធាវីឃ្លាំមើលសិទ្ធិនៃប្រទេសកាណាដា ហៅកាត់ថា (LRWC) ដែលជាគណៈ កម្មការមេធាវី ជនជាតិកាណាដាធ្វើការលើកស្ទួយសិទ្ធិមនុស្ស ធម្មាធិបតេយ្យ និងនីតិរដ្ឋលើផ្ទៃរាបអន្តរ ជាតិ។ អង្គការ LRWC ផ្តល់ការគាំទ្រផងដែរចំពោះមេធាវី និងអ្នកការពារសិទ្ធិមនុស្សដែលទទួលរង គ្រោះដោយសារការធ្វើសកម្មភាពតស៊ូមតិ។

អង្គការ LRWCមានការព្រួយបារម្ភចំពោះការចាប់ខ្លួនលោកគុជវ៉េងសកម្មជនសិទ្ធិដីធ្លី និងជាអ្នកដឹកនាំ

សហគមព្រៃឈើ ហើយក៏ជាសមាជិកបណ្តាញកសាងសន្តិភាពសហគមដែលត្រូវបានចាប់ខ្លួនកាលពី

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៣ ប្រហែលម៉ោង៩.៣០នាទីព្រឹកដោយកំលាំងនគរបាលចំនួន៤នាក់ នៅ

ឯឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិសាត់។ ក្នុងពេលចាប់ខ្លួន លោកគុជវ៉េងកំពុងតែចុះជួបប្រជា

ពលរដ្ឋ១០គ្រួសារដែល មានជំលោះដីធ្លីជាមួយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចភាភីម៉ិចដែលជាសហ គ្រាសដ៏ធំរបស់**លោកស្រីជឹង សុភាព**(ហៅក្រៅថាយាយភូ)ភរិយានៃអ្នកជំនួញដ៏មានឥទ្ធិពលម្នាក់ និងជាសមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា គឺលោក ឡៅ ម៉េងឃីន។

មន្ត្រីនគរបាលត្រូវបានគេរាយការណ៍ថា ពុំបានបង្ហាញដីកាចាប់ខ្លួន ឬពុំបានរៀបរាប់អំពីមូលហេតុនៃ

ការចាប់ខ្លួនដល់លោក គុជ វ៉េងឡើយ។ មន្ត្រីនគរបាលបានប្រាប់អ្នកភូមិថា បើពួកគេចង់ដឹងអំពីបទ

ចោទប្រកាន់ ពួកគេអាចទៅសួរនាំឯអធិការដ្ឋាននគរបាលស្រុក។ បន្ទាប់មក លោក គុជ វ៉េងត្រូវបានសមត្ថកិច្ចនាំខ្លួនមកតុលាការខេត្តពោធិសាត់នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ វេលាម៉ោងប្រហែល ៩.០០នាទីព្រឹក។ ហើយនៅមិនទាន់ត្រូវបានដោះលែងឡើយ ។

ថ្វីត្បិតថានៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ លោក គុជ វ៉េងនឹងត្រូវនាំមកសួរចំលើយនៅឯតុលាការ ខេត្តពោធិសាត់ដោយចៅក្រមស៊ើបសួរពាក់ពន្ធ័សំណុំរឿងឆបោកតាំងពីឆ្នាំ២០១០ក៏ដោយ ក៏អង្គការ

LRWCនៅតែជឿថាការចាប់ខ្លួននេះមានទាក់ទងដល់សកម្មភាពការងារស្របច្បាប់និងដោយសន្តិវិធី

ដែលគាត់ធ្វើក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សម្នាក់ ពុំមែនទាក់ទិននិងអំពើឆបោកឡើយ។ លោក គុជ

វ៉េង បានចាប់ផ្តើមធ្វើការងារយ៉ាងសកម្មទាមទារសិទ្ធិដីធ្លីតាំងពីឆ្នាំ២០០០នៅពេលដែលក្រុមហ៊ុនភាភី

ម៉ិចចាប់ផ្តើមសកម្មភាពឈូសឆាយដីព្រៃក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ខ្លួន។ គាត់បានចូលរួម

ក្នុងបណ្តាញកសាងសន្តិភាពសហគមតាំងពីឆ្នាំ២០១០មកម្ល៉េះ។ គាត់ធ្លាប់ទទួលរងគ្រោះពីការចាប់ ខ្លួនដោយសារតែសកម្មភាពជួយទាមទារសិទ្ធិដីធ្លីកន្លងមកដែរ។ ការចាប់ខ្លួននៅ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៣គឺជាករណីដែលកំពុងបញ្ជាក់អំពីស្ថានភាពនៃការចាប់ និងឃុំខ្លួនតាមអំពើចិត្តចំពោះអ្នកការ

ពារសិទ្ធិមនុស្សទូទៅ។ ជាញឹកញាប់ណាស់ជនរងគ្រោះនៃការចាប់និងឃុំខ្លួនតាមទំនើងចិត្ត ភាគច្រើន ជាមនុស្សការពារ លើកស្ទួយសិទ្ធិរបស់សមាជិកសហគមដែលមានជំលោះដីធ្លីជាមួយម្ចាស់សហ គ្រាស ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចដែលមានទំនាក់ទំនង និងឥទ្ធិពលជាមួយមន្ត្រីរាជរដ្ឋាភិបាល។

បើទោះបីមានការចោទប្រកាន់បទល្មើសឆបោកតាំងពីឆ្នាំ២០១០ក៏ដោយ ក៏លោក គុជវ៉ែងនៅមានសិទ្ធិ

ត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោស ហើយគួរត្រូវបានដោះលែងនៅក្រៅឃុំរង់ចាំកាត់សេចក្តី អនុ

លោមតាមគោលការណ៍មានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ដែលប្រទេសកម្ពុជាជារដ្ឋភាគីផងដែរ។ សិទ្ធិត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោសដ៏រាប

ណាតុលាការមិនទាន់ផ្តន្ទាទោសជាស្ថាពរត្រូវបានទទួលស្គាល់ដោយសេចក្តីប្រកាសជាសកលស្តីអំពី

សិទ្ធិមនុស្ស (UDHR) ត្រង់មាត្រា១១(១) និងធានាដោយ ICCPRត្រង់មាត្រា១៤(២) ។ សេរីភាពពីការ

ចាប់ឃុំខ្លួនតាមទំនើងចិត្ត និងសិទ្ធិត្រូវបានដោះលែងនៅក្រៅឃុំទទួលស្គាល់ត្រង់មាត្រា៣និងមាត្រា៩នៃUDHR ហើយធានាដោយមាត្រា១៤(២)នៃICCPR។ គោលការណ៍ច្បាប់ចែងក្នុង UDHR និងICCPR

មិនបញ្ចូលការឃុំខ្លួនបណ្តោះអាសន្នទេដ៏រាបណាវាមិនមែនជាការចាំបាច់ដូចជាដើម្បីការពារសុវត្ថភាពសាធារណៈ ធានាការមិនគេចវេសពីតុលាការ និង/ឬការពារមិនឲ្យមានការជ្រៀតជ្រែកភស្តុតាង។

រដ្ឋធម្មនុញ្ញកម្ពុជាបានធានា និងទទួលស្គាល់យ៉ាងជាក់លាក់ ហើយគោរព UDHR និងICCPR ដោយ

ចែងត្រង់មាត្រា៣៨ថា (ជនជាប់ចោទត្រូវបានសន្មត់ថាជាជនគ្មានទោសដ៏រាបណាតុលាការមិនទាន់ ផ្តន្ទាទោសជាស្ថាពរ)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមាត្រា២០៣បញ្ជាក់អះអាងនូវគោលការណ៍ទាំង នេះ ហើយត្រូវតែបកស្រាយឲ្យស្របតាម UDHR និង ICCPR ។ អង្គការ LRWCពុំបានទទួលព័ត៏មាន

ថាមានការចោទប្រកាន់ និងភស្តុតាងស្របច្បាប់ណាមួយដែលគួរបន្តការឃុំខ្លួន គុជ វ៉ែង ដូចនេះគាត់

គួរត្រូវបានដោះលែងឲ្យមានសេរីភាពជាបន្ទាន់។

អ្នកការពារសិទ្ធិមនុស្សដូចជា លោក គុជ វ៉ែង មានសិទ្ធិគ្រប់គ្រាន់ដើម្បីធ្វើការតស៊ូមតិដើម្បីសិទ្ធិមនុស្ស

ដោយសន្តិវិធី ហើយគួរត្រូវទទួលបានការការពារពីទំរង់នានានៃការសងសឹករួមមានការចាប់ឃុំខ្លួន តាមទំនើងចិត្ត ការបង្ក្រាបនិងការកាត់ទោសដោយអំណាចតុលាការ។ សេចក្តីប្រកាសរបស់សហ ប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស អនុម័តតាំងពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៨ដោយមតិឯកច្ឆន្ទ័នៃមហា សន្និបាតអង្គការសហប្រជាជាតិថ្លែងថា:

- ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃចូលរួមក្នុងសកម្មភាពសន្តិ វិធីប្រឆាំងនិងការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មានចែងត្រង់មាត្រា១២(១)។

- ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃក្នុងការលើកស្ទួយ និងការខំ ប្រឹងប្រែងការពារ និងធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ មានចែងត្រង់មាត្រា១។

- រដ្ឋត្រូវចាត់វាល់វិធានការចាំបាច់ដើម្បីធានាឲ្យមាននូវការការពារពីអាជ្ញាធរមានសមត្ថកិច្ចចំពោះជនគ្រប់រូប ដោយម្នាក់ៗឯងនិងដោយរួមជាមួយអ្នកដទៃ ប្រឆាំងនិងអំពើហឹង្សា ការគំរាម កំហែង ការសងសឹក ការរើសអើងជាអវិភូតជាក់ស្តែង ឬតាមផ្លូវច្បាប់ ការគាបសង្កត់ ឬសកម្មភាពតាមអំពើចិត្តផ្សេងទៀត ដោយសារតែការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួនដែលមានចែងក្នុងសេចក្តីប្រកាសនេះ យោងមាត្រា១២(២)។

អ្នកការពារសិទ្ធិមនុស្សដូច លោក គុជ វ៉េង គឺមានសិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពតស៊ូមតិដោយ សន្តិវិធីដើម្បីលើកស្ទួយសិទ្ធិមនុស្ស ហើយគាត់គួរត្រូវបានការពារពីការសងសឹក និងការគំរាមកំហែងពីអំណាចតុលាការគ្រប់ទំរង់ទាំងអស់។

អង្គការ LRWC ស្នើសុំឲ្យមានការចាត់វិធានការចាំបាច់នានាជាបន្ទាន់ដើម្បី:

- ដោះលែង លោក គុជ វ៉េងភ្លាមៗ

- ទំលាក់ចោលនូវបទចោទប្រកាន់ដែលបំផ្លើសចំពោះលោក គុជ វ៉េងភ្លាមៗ និងគ្មានលក្ខណ្ឌ

- ធានាចំពោះសុវត្ថភាពផ្លូវកាយ និងផ្លូវចិត្តរបស់ លោក គុជ វ៉េង

យើងស្នើសុំរាជរដ្ឋាភិបាលរបស់លោកឲ្យធានាថា គ្រប់ចៅក្រម ព្រះរាជអាជ្ញានិងមន្ត្រីដទៃទៀតនៃរឿង ក្តីនេះធ្វើការ និងអនុវត្តអំណាចដោយមិនលំអៀងអនុលោមតាមច្បាប់ រួមមានកាតព្វកិច្ចច្បាប់ដែលត្រូវបានទទួលស្គាល់ និងបង្កើតឡើងដោយសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរ ជាតិ ICCPR និងបទដ្ឋានអប្បរិមាស្តីអំពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ ដែលគោលការណ៍ទាំងនោះចែងអំពីភារៈ កិច្ចរបស់រដ្ឋដើម្បីធានានូវឯករាជ្យ ភាពមិនលំអៀង និងការដែលមិនអាចជ្រៀតជ្រែកបាន នៃប្រព័ន្ធតុលាការ។

អង្គការ LRWC ក៏ស្នើសុំរាជរដ្ឋាភិបាលរបស់លោកឲ្យធានាផងដែរ (១) សុវត្ថភាពនៃអ្នកការពារសិទ្ធិ មនុស្សទាំងឡាយដែលកំពុងធ្វើការតស៊ូមតិសំរាប់សិទ្ធិសហគម និងសិទ្ធិរបស់ជននិមួយៗក្នុងការកាន់កាប់ ប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ (២) បញ្ឈប់ជាបន្ទាន់រាល់ទំរង់នៃការគំរាមកំហែងដល់អ្នកការ ពារសិទ្ធិមនុស្ស រួមមានសកម្មជនសិទ្ធិដីធ្លី អ្នកសារព័ត៏មាន និងអ្នកទាំងឡាយណាដែលទាមទារ ឲ្យប្រទេសកម្ពុជា គោរពនូវកាតព្វកិច្ចធម្មនុញ្ញ និងកាតព្វកិច្ចច្បាប់អន្តរជាតិរបស់ខ្លួន។

ដោយសេចក្តីគោរពរាប់អានដ៏ស្មោះ!

ហត្ថលេខា

**ហ្គេល ដាវីសុន**

អគ្គនាយក អង្គការមេធាវីឃ្លាំមើលសិទ្ធិនៃប្រទេសកាណាដា(LRWC)